# សេចក្តីប្រកាសព័ត៌មាន

## ក្រុមការងារស្តីពីសិទ្ធិទទួលបានព័ត៌មានប្រារព្ធទិវាអន្តរជាតិសិទ្ធិទទួលបានព័ត៌មានជាសកល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា៖ ក្រុមអង្គការសង្គមស៊ីវិល (CSOs) នៅកម្ពុជានឹងរៀបចំសិក្ខាសាលាថ្នាក់ជាតិ ក្នុងឱកាសទិវាអន្តរជាតិសិទ្ធិទទួលបានព័ត៌មានជាសកល (IDUAI)។

**ព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ នៅសណ្ឋាគារសាន់វ៉េ ក្នុងរាជធានីភ្នំពេញ។**

ក្រោមប្រធានបទ "**ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងជំរុញការវិនិយោគ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា**" សិក្ខាសាលានេះមានគោលបំណងជំរុញការអនុម័ត និងការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលគ្រប់ជ្រុងជ្រោយនៅក្នុងប្រទេស។

សិក្ខាសាលានេះនឹងមានការអញ្ជើញចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗជាង៣៣០ នាក់ ដែលរួមមានអ្នកធ្វើគោលនយោបាយ មន្ត្រីរាជរដ្ឋាភិបាល និងតំណាងគណបក្សនយោបាយ វិស័យឯកជន បណ្តាញផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល យុវជន និងសហគមន៍។ អ្នកចូលរួមនឹងពិភាក្សាអំពីសារៈសំខាន់ជាសារវន្តនៃសិទ្ធិទទួលបានព័ត៌មាន ក្នុងការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អ។

សិទ្ធិទទួលបានព័ត៌មាន គឺជាគ្រឹះដ៏សំខាន់នៃសេរីភាពសម្តែងមតិ ហើយវាជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលជំរុញការវិនិយោគ និងកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមដោយពេញលេញក្នុងភាពជាពលរដ្ឋ។ យើងមានជំនឿថា ប្រជាពលរដ្ឋដែលមានព័ត៌មានសំខាន់ក្នុងដៃ អាចការពារសិទ្ធិរបស់ខ្លួន និងជំរុញឱ្យរដ្ឋាភិបាលទទួលខុសត្រូវ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ន ប្រជាពលរដ្ឋកម្ពុជាមិនទាន់ទទួលបានព័ត៌មានដែលពួកគេត្រូវការ ដើម្បីអាស្រ័យផលសិទ្ធិ និងសេវាដែលពួកគេស័ក្តិសមនឹងទទួលបាននៅឡើយ។

អង្គការសង្គមស៊ីវិលជាសមាជិកនៃក្រុមការងារស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2IWG) បានធ្វើការតស៊ូមតិលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានជារៀងរាល់ឆ្នាំ រយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយស្នើឱ្យរាជរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់សាធារណជន។

សិក្ខាសាលានេះមានគោលបំណង៖

- **ដំណើរការឡើងវិញរបៀបវារៈច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងបញ្ចុះបញ្ចូលអ្នកធ្វើគោលនយោបាយ** - ដើម្បីតស៊ូមតិលើការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានឱ្យបានឆាប់រហ័ស ដោយជំរុញឱ្យអ្នកធ្វើសេចក្តីសម្រេចផ្តល់អាទិភាពលើច្បាប់ដ៏សំខាន់នេះ។
- **បង្កើនការយល់ដឹងជាសាធារណៈ** - ដើម្បីបង្កើនការយល់ដឹងរបស់សាធារណជនអំពីសារៈសំខាន់នៃសិទ្ធិទទួលបានព័ត៌មាន និងអត្ថប្រយោជន៍របស់ច្បាប់នេះសម្រាប់សេដ្ឋកិច្ច បុគ្គលម្នាក់ៗ សហគមន៍ និងសង្គមទាំងមូល។

ដោយជំរុញកិច្ចសន្ទនា និងកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធចម្រុះ សិក្ខាសាលានេះព្យាយាមបង្កើតសន្ទុះដ៏ក្លៀវក្លាជំរុញការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលនឹងផ្តល់ភាពអង់អាចដល់ប្រជាពលរដ្ឋ និងជំរុញឱ្យរដ្ឋាភិបាលកាន់តែមានតម្លាភាព និងគណនេយ្យភាព។

សម្រាប់ព័ត៌មានបន្ថែម ឬការចុះឈ្មោះចូលរួម សូមទាក់ទង៖ ០៩៨ ៨៦ ២២ ៥៥